# ភាពជោគជ័យស្ត្រីក្លាយជាអ្នកគ្រប់គ្រង

១- ប្រវត្តិរបស់ក្រុមស្ត្រីអភិវឌ្ឍន៍រីកចំរើន

ក្រុមស្ត្រីអភិវឌ្ឍន៍រីកចំរើន គឺជាក្រុមមួយដែលស្ថិតនៅក្នុងភូមិសំរោងជើង ឃុំសំរោងស្រុកសូទ្រនិគម ខេត្តសៀមរាប។ ក្រុមនេះត្រូវបានបង្កើតឡើងដោយប្រជាជនស្ម័គ្រចិត្ត នៅថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០០៧ ក្រោមការជួយឧបត្ថមគាំទ្រពីអង្គការអាដដា និង អង្គការរីដា។ ដំបូងក្រុមស្ត្រីអភិវឌ្ឍន៍រីកចំរើនមានសមាជិកសរុបចំនួន ១៥ នាក់ ក្នុងនោះមានស្ត្រី ចំនួន ១៤នាក់ តែនៅពេលបច្ចុប្បន្នក្រុមនេះមានសមាជិក ១៨នាក់ ដែលមានស្ត្រីចំនួន ១៧នាក់។ ក្រុមនេះមានមុខរបរជាច្រើនដូចជា ទិញលក់ជី, ចិញ្ចឹមសត្វ និងផ្តល់កម្ចីឥទានដល់សមាជិកក្រុម។

២- ស្ថានភាពក្រុមមុនពេលចូលគំរោង

មុនពេលចូលជាអ្នកទទួលផលនៅក្នុងគំរោង ចំរុះបង្កើនសិទ្ធិ អំណាចដល់ស្ត្រី, ប្រជាជន ដែលរស់នៅក្នុងភូមិសំរោងជើង ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប បានរស់នៅជា លក្ខណៈដាច់ដោយឡែកពីគ្នា, ពុំសូវមានការសាមគ្គីគ្នា និងប្រកបរបររៀងៗខ្លួនតាមយថាផលមានដូចជា: ធ្វើស្រែ, ដាំបន្លែ និងចិញ្ចឹមសត្វជាដើម ដោយទទួលបានផលទាបដែលជាហេតុធ្វើអោយជីវភាពរស់នៅរបស់ពួកគាត់ពុំសូវធូធារសំបូរសប្បាយ។ ការប្រកបរបរពេលនោះ គឺពួកគាត់នាំគ្នាធ្វើទៅតាមទំលាប់ពីមុនៗមក ដោយមិនបានដឹងឬមិនចេះពីបច្ចេកទេស នៃការធ្វើកសិកម្មដាំដុះ និងចិញ្ចឹមសត្វនោះទេ។ ម្យ៉ាងវិញទៀតពួកគាត់ក៏មិនដឹង/មិនយល់ពីក្រុមជួយខ្លួនឯង ដែលជាហេតុធ្វើអោយពួកគាត់មានការពិបាកយ៉ាងខ្លាំងក្នុងការស្វែងរកប្រភពទុនពីអ្នកក្រៅ និង ស្ថាប័នឥទាណនានា ដើម្បីប្រកបរបរចិញ្ចឹមជីវិត។

អង្គការអាដដាបានទទួលជំនួយពីប្រទេសដាណឺម៉ាក តាំងពីឆ្នាំ២០០៥ នៅក្នុងខេត្តសៀមរាប និងបានចាប់ដៃគូរសហប្រត្តិបត្តការណ៍យ៉ាងជិតស្និតជាមួយអង្គការរីដាកម្ពុជា ហើយបានចុះផ្សព្វផ្សាយពីគោលបំណងរបស់គំរោង និងជ្រើសរើសកសិករដែលស្ម័គ្រចិត្ត នៅថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៧ នៅតាម ភូមិគោលដៅមកចូលរួមរៀនវគ្គបណ្តុះបណ្តាលពីសាលារៀនស្រែកសិករចំរុះ។ ដោយឃើញពីសារៈ ប្រយោជន៍ដូចនេះ ពួកគាត់មានចំណាប់អារម្មណ៍យ៉ាងខ្លាំង ហើយក៏បានចុះឈ្មោះចូលរៀនវគ្គសាលាស្រែ កសិករចំរុះ។

៣- កំឡុងពេលចូលគំរោង

សាលារៀនស្រែកសិករត្រូវបានបើកវគ្គនៅ ខែសីហា ឆ្នាំ ២០០៧ ដោយមានអ្នកចូលរួមសរុបចំនួន ៤៨នាក់ ស្រី ៣៧នាក់ ក្នុងនោះកសិករចំនួន ២៣នាក់ ស្រី ១២នាក់បានចូលរួមវគ្គដាំបន្លែ (ការដាំប៉េងបោះ, ការដាំត្រសក់) និងកសិករចំនួន ២៥នាក់ដែលសុទ្ធតែជាស្ត្រីទាំងអស់បានចូលរួមវគ្គចិញ្ចឹមជ្រូកសាច់។ ការបើកវគ្គបណ្តុះបណ្តាលនេះបានធ្វើអោយកសិករមានការចាប់អារម្មណ៍ជាខ្លាំង។ ក្រោយពីវគ្គសាលា ស្រែកសិករត្រូវបានបញ្ចប់ កសិករចំនួន ១៥នាក់បានស្ម័គ្រចិត្ត និងឯកភាពគ្នា បង្កើតជា ក្រុមមួយហៅថាក្រុមស្ត្រីអភិវឌ្ឍន៍រីកចំរើន។ ក្រុមស្ត្រីអភិវឌ្ឍន៍រីកចំរើន បានចាប់ផ្តើមពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៧ គឺក្រោយពីការបញ្ចប់វគ្គសាលាស្រែកសិករដែលមានសមាជិកសរុបចំនួន ១៥នាក់ ស្រី ១៤នាក់។ សមាជិកម្នាក់ៗបានសំរេចគ្នាដាក់ប្រាក់សន្សំចំនួន ២,០០០រៀលក្នុងមួយសប្តាហ៍ដើម្បីទុក ជាទុនប្រកបរបរ ក្នុងក្រុម។ គណៈកម្មាការចំនួន ៣នាក់ត្រូវបានជ្រើសរើសចេញពីក្រុម ដោយមានការឯក ភាពគ្នាពីសមាជិក ក្រុម និងមានការសម្របសម្រួលពីបុគ្គលិកអង្គការអាដដា។ គណៈកម្មាការក្រុម គឺជាអ្នក ដឹកនាំក្រុម ហើយជា

មនុស្សឧស្សាហ៍ព្យាយាម ឆ្លាតវៃ និងម៉ឺងម៉ាត់ទាំងការងារក្រុម ក៏ដូចជាគ្រួសារ។ ម្យ៉ាង ទៀតសមាជិកក្រុមម្នាក់ៗបានទទួលប្រាក់ឧបត្ថមពីអង្គការអាដដាចំនួន ២៥ ដុល្លាសំរាប់ជាទុនក្នុងក្រុម។

បច្ចុប្បន្ន ក្រុមនេះមានសមាជិកសរុបចំនួន ១៨នាក់ ស្រី ១៧នាក់ ហើយបានដាក់ប្រាក់សន្សំចំនួន ៩,០០០រៀល ក្នុងរយៈពេល ២សប្តាហ៍ម្តង និងបានចែកផលលាភពីការប្រាក់ និងជំនួញទៅអោយសមាជិកក្រុមមួយឆ្នាំម្តង។

ការលះបង់ពេលវេលា, ការឆ្លាតវៃ, ការគោរពតួនាទី និងការគោរពច្បាប់ក្រុម ពីគណៈកម្មាការ និង សមាជិកក្រុម បានធ្វើអោយក្រុមនេះមានលទ្ធផលល្អរហូតមកដល់បច្ចុប្បន្ន។ ម្យ៉ាងទៀតគណៈកម្មាការក្រុម បានចូលរួមវគ្គបណ្តុះបណ្តាលបន្ថែមពីអង្គការអាដដា-វីដា ក៏ដូចជាការចូលរួមប្រជុំជាមួយភូមិ ឃុំ និងប្រជុំជាមួយអង្គការផ្សេងៗទៀតដើម្បីទទួល និងចែករំលែកបទពីសោធន៍ដល់ក្រុម។ ទាំងនេះធ្វើអោយពួកគាត់កាន់តែមានបទពីសោធន៍បន្ថែមទៀតក្នុងការដឹកនាំក្រុមអោយកាន់តែរីកចំរើនទៅមុខ។

***<u>សកម្មភាពប្រជុំក្រុម</u>***





***<u>សកម្មភាពជំនួញក្រុម</u>***





## *សកម្មភាពចិញ្ចឹមសត្វ*





**៤- ក្រោយពេលចូលគំរោង**

ជីវភាពរបស់សមាជិកម្នាក់ៗនៅក្នុងក្រុមស្ត្រីអភិវឌ្ឍន៍រីកចំរើន មានការផ្លាស់ប្តូរបន្តិចម្តងៗតាមរយៈការដាំបន្លែ, ចិញ្ចឹមសត្វ និងជំនួញជាក្រុម និងជាបុគ្គល។ ក្នុងមួយខែជាមធ្យមពួកគាត់អាចរកចំណូលពីការលក់បន្លែ, ចិញ្ចឹមមាន់ និងជំនួញជាបុគ្គលបានចំនួន ១២០,០០០រៀល ដែលកាលពីមុនពេលចូលគំរោងសូម្បីតែដាំ និងចិញ្ចឹមសត្វសំរាប់ហូបក៏មិនគ្រប់គ្រាន់ផង។ ការដាំដុះរបស់ពួកគាត់បានផ្លាស់ប្តូរពីការដាំតាមទំលាប់ មកជា ការដាំតាមលក្ខណៈបច្ចេកទេស ហើយទទួលបានផលគួរជាទីពេញចិត្ត។ ម្យ៉ាងទៀតជំនួញជាក្រុមក៏ជាផ្នែក មួយនៃចំណូលសំរាប់គ្រួសារ និងក្រុមរបស់គាត់ផងដែរ។ ប្រាក់ចំណូលដែលបានមកពីការធ្វើជំនួញ និងការប្រាក់ត្រូវបានដក ៣០%សំរាប់បង្កើនទុន និង៧០%ទៀតសំរាប់ចែកអោយសមាជិកម្នាក់ៗក្នុងក្រុម។ ការបែងចែកចំណូលពីការធ្វើជំនួញ និងការប្រាក់ត្រូវបានធ្វើរៀងរាល់បំណាច់ឆ្នាំម្តង។ បច្ចុប្បន្នក្រុមនេះ មានទុនសរុបចំនួនជាង ៣,០០០ដុល្លា ដែលចំនួនទុនទាំងនេះបានមកពីប្រាក់ឧបត្ថមកំឡុងពេលចូលគំរោង (២៥ដុល្លាក្នុងម្នាក់), ប្រាក់សន្សំរបស់សមាជិករៀងរាល់ ២ សប្តាហ៍ម្តង, ការប្រាក់ និងជំនួញជាក្រុម។

ដោយសារការគ្រប់គ្រងពីសំណាក់គណៈកម្មាការក្រុម និងការជួយបណ្តុះបណ្តាលពីអង្គការអាជដា និងអង្គការវីដាកម្ពុជាសមាជិកម្នាក់ៗមានការដាំបន្លែ, និងចិញ្ចឹមសត្វបានល្អ ហើយជំនួញរបស់ពួកគាត់ក៏កាន់តែរលូនទៅមុខ និងដោយការឧស្សាហ៍ព្យាយាម មឹងម៉ាត់ ,គោរពវិន័យ បានធ្វើអោយក្រុមស្ត្រីអភិវឌ្ឍន៍ក្លាយជាក្រុមគំរូមួយ នៅក្នុងឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប។ បច្ចុប្បន្នក្រុមនេះដឹកនាំដោយស្ត្រីដោយមានការទទួលស្គាល់ពីអាជ្ញាធរភូមិ ឃុំ។